ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៥.......សហវ.......

# សេចក្ដីណែនាំ
# ស្ដីពី
# នីតិវិធីនៃការកត់ត្រាលើសន្លឹកអាណត្តិបើកប្រាក់ និងនីតិវិធីនៃការកត់ត្រាក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

យោង៖
- ប្រកាសលេខ៧៧២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាល នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រ នៃមាតិកាថវិកា
- ប្រកាសលេខ ៥៤៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រ នៃមាតិកាថវិកា
- ប្រកាសលេខ ៧៣២ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មូលនិធិ នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨៨២ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់គម្រោង នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធី នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងគោលបំណងធានាឱ្យការកត់ត្រាលើសន្លឹកអាណត្តិបើកប្រាក់ ដែលមានប្រាំពីរ (៧)ចំណាត់ថ្នាក់ថវិកាតាមគំរូអាណត្តិថ្មី និងការកត់ត្រាប្រតិបត្តិការចំណាយថវិកា ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS) របស់ក្រសួង ស្ថាប័នអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ថ្នាក់ក្រោមជាតិ ឱ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវនីតិវិធីមួយចំនួនដូចខាងក្រោម÷

## ក-នីតិវិធីនៃការកត់ត្រាលើសន្លឹកអាណត្តិបើកប្រាក់

សន្លឹកអាណត្តិបើកប្រាក់ ត្រូវបានចែកចេញជាពីរផ្នែកគឺ ផ្នែកខាងលើ និងផ្នែកខាងក្រោម ដែលមានព័ត៌មានដូចគ្នា និងត្រូវកត់ត្រាដូចគ្នា។ សម្រាប់ការកត់ត្រាព័ត៌មានសំខាន់ៗចាំបាច់លើ **សន្លឹកអាណត្តិបើកប្រាក់** ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

១.ក្រសួង: ប្រើសម្រាប់ការកត់ត្រាឈ្មោះក្រសួងឬ ស្ថាប័ន ដែលជាអ្នកទទួលបន្ទុកចំណាយ។ ឧទាហរណ៍÷ ក្រសួងអប់រំ យុវជន និងកីឡា។

២.រាជធានីខេត្ត: ប្រើសម្រាប់ការកត់ត្រាឈ្មោះរាជធានី ឬ ខេត្ត ដែលមន្ទីរជំនាញ ឬ អង្គភាពថវិកា ឬប្រើប្រាស់សម្រាប់កត់ត្រាឈ្មោះ**ផ្នែក**នៅថ្នាក់កណ្តាល។ ឧទាហរណ៍÷ រាជធានី-ខេត្ត: សៀមរាប, រាជធានី-ខេត្ត: ផ្នែកអប់រំ។

៣.លេខអាណត្តិ: លេខអាណត្តិបើកប្រាក់មាន ៤ ខ្ទង់។ ឧទាហរណ៍÷ អាណត្តិលេខ ១ របស់ក្រសួងអប់រំ យុវជន និងកីឡា (ផ្នែកអប់រំ) គឺត្រូវកត់ត្រា ០០០១។

៤.លេខកូដប្រព័ន្ធ: ជាប្រអប់ដែលប្រើសម្រាប់កត់ត្រានូវលេខកូដដែលបង្កើតដោយប្រព័ន្ធ FMIS ហៅថាលេខសក្ខីបត្រ (Voucher ID) និងប្រើប្រាស់សម្រាប់តែអង្គភាពដែលអនុវត្តប្រព័ន្ធ FMIS តែប៉ុណ្ណោះ។ នៅពេលប្រតិបត្តិការចំណាយត្រូវបានបង្កើតនៅក្នុងប្រព័ន្ធ នោះប្រព័ន្ធនឹងផ្តល់នូវលេខកូដនេះដោយស្វ័យប្រវត្តិ។

៥.រដ្ឋបាល: ព័ត៌មាននៅក្នុងផ្នែកនេះមានចំនួនខ្ទង់សរុបទាំងអស់ចំនួន ៧ ខ្ទង់។ ឧទាហរណ៍÷ ចំណាយចេញពីអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល មានលេខកូដ [១][២][០][២][ ][ ][ ] មន្ទីរពេទ្យកុមារជាតិមានលេខកូដ [១][២][០][៦][០][៦][ ] រដ្ឋបាលខេត្តបន្ទាយមានជ័យ មានលេខកូដ [៩][០][១][ ][ ][ ][ ] រដ្ឋបាលក្រុងសិរីសោភណ្ឌនៃខេត្តបន្ទាយមានជ័យ មានលេខកូដ [៩][០][១][០][៦][ ][ ] រដ្ឋបាលសង្កាត់កំពង់ស្វាយ នៃក្រុងសិរីសោភ័ណ មានលេខកូដ [៩][០][១][០][៦][០][២]។

៦.ភូមិសាស្ត្រ ព័ត៌មាននៅក្នុងផ្នែកនេះមានចំនួនខ្ទង់សរុបទាំងអស់ចំនួន ៦ ខ្ទង់។ ឧទាហរណ៍÷ សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានលេខកូដ [១][២][០][៦][០][៨]សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបងមានលេខកូដ [០][២][០][៣][០][១] ។ ក្នុងករណីដែលមានទីតាំងភូមិសាស្ត្រច្រើនលើសពី១ សម្រាប់អាណត្តិបើកប្រាក់មួយសន្លឹក នោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធលម្អិតអមជាមួយ ដើម្បីជាមូលដ្ឋានក្នុងការកត់ត្រាបញ្ចូលក្នុងប្រព័ន្ធ FMIS។ ក្នុងន័យនេះ ករណីមានរាជធានី ខេត្តច្រើន នោះសន្លឹកអាណត្តិបើកប្រាក់អាចចំហរមិនចាំបាច់បំពេញនោះទេ ហើយបើសិនជារាជធានី ឬ ខេត្ត១ មានក្រុងស្រុកច្រើនលើសពី១ នោះគឺត្រូវបំពេញត្រឹមលេខកូដរាជធានី ឬ ខេត្តប៉ុណ្ណោះ តែបើសិនជារាជធានី ឬ ខេត្ត១ មានក្រុង ឬ ស្រុក១ ហើយមានឃុំ សង្កាត់ច្រើនលើសពី១ នោះគឺត្រូវបំពេញលេខកូដរាជធានី ឬ ខេត្ត និងលេខកូដក្រុង ឬ ស្រុកប៉ុណ្ណោះ ដោយអាចចំហរមិនបំពេញលេខកូដឃុំ សង្កាត់។

៧.<u>មុខងារ:</u> ព័ត៌មាននៅក្នុងផ្នែកនេះមានសរុបទាំងអស់ចំនួន ៥ ខ្ទង់។ នៅក្នុងផ្នែកនេះ នៅលើសន្លឹកអាណត្តិបើកប្រាក់មិនតម្រូវឱ្យធ្វើការបំពេញឡើយ ដោយចំណាត់មុខងារ នឹងត្រូវបង្កើតឡើងដោយស្វ័យប្រវត្តិជាមួយចំណាត់កម្មវិធី ដើម្បីជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍តាមរយៈប្រព័ន្ធ FMIS។

៨.<u>មូលនិធិ:</u> ព័ត៌មាននៅក្នុងផ្នែកនេះមានសរុបទាំងអស់ចំនួន ៥ ខ្ទង់។ ឧទាហរណ៍÷ លេខកូដ |២|១|១|០|៨| ជាមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) របស់ដៃគូអភិវឌ្ឍន៍ពហុភាគី នៃមូលនិធិពិសេសរបស់ហិរញ្ញប្បទានឥតសំណង។ លេខកូដ |៣|១|២|០|១| ជាឥណទានសម្បទាន នៃមូលនិធិពិសេស របស់ដៃគូអភិវឌ្ឍន៍ ទ្វេភាគី ពីសាធារណៈរដ្ឋប្រជាមានិតចិន។

៩.<u>កម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព:</u> ព័ត៌មាននៅក្នុងផ្នែកនេះមានសរុបទាំងអស់ចំនួន ៨ ខ្ទង់។ ឧទាហរណ៍÷ លេខកូដ |០|៩|១|០|១|០|៣| | គឺចង្កោមសកម្មភាពទី៣ នៃអនុកម្មវិធីទី១ ក្នុងកម្មវិធីទី១ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, លេខកូដ |០|៥|៣|២|០|១|០|៣| គឺចង្កោមសកម្មភាពទី៣ នៃអនុកម្មវិធីទី១ ក្នុងកម្មវិធីទី២ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។ ក្នុងករណីដែលមានចំនួនចង្កោមសកម្មភាព ឬអនុកម្មវិធី ឬកម្មវិធី លើសពី១ សម្រាប់អាណត្តិបើកប្រាក់មួយសន្លឹក នោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធលម្អិតអមមកជាមួយ ដើម្បីជាមូលដ្ឋានក្នុងការកត់ត្រាបញ្ចូលក្នុងប្រព័ន្ធ FMIS។ ក្នុងន័យនេះករណីមានកម្មវិធីច្រើន នោះសន្លឹកអាណត្តិបើកប្រាក់អាចចំហរមិនបំពេញនោះទេ ហើយបើសិនជាកម្មវិធី១ មានអនុកម្មវិធីច្រើនលើសពី១ នោះគឺត្រូវបំពេញត្រឹមលេខកូដកម្មវិធីប៉ុណ្ណោះ តែបើសិនជាកម្មវិធី១ មានអនុកម្មវិធី១ ហើយមានចង្កោមសកម្មភាពច្រើនលើសពី១ នោះគឺត្រូវបំពេញលេខកូដកម្មវិធី និងលេខកូដអនុកម្មវិធីប៉ុណ្ណោះ ដោយអាចចំហរមិនបំពេញលេខកូដចង្កោមសកម្មភាព។

១០.<u>គម្រោង:</u> ព័ត៌មាននៅក្នុងផ្នែកនេះមានទាំងអស់ចំនួន ៦ ខ្ទង់។ ឧទាហរណ៍លេខកូដ |០|០|០|០|១|៨| ជាគម្រោងអភិវឌ្ឍន៍ជនបទភូមិភាគពាយ័ព្យ(ADB-1862-CAM), លេខកូដ |០|០|០|០|៩|៧| គម្រោងអភិវឌ្ឍន៍វិស័យធារាសាស្ត្រ និងកសិកម្ម (AFD-1132-02-J)។

១១.សេដ្ឋកិច្ច (<u>ជំពូក-គណនី-អនុគណនី):</u> ព័ត៌មាននៅក្នុងផ្នែកនេះមានទាំងអស់ចំនួន ៥ ខ្ទង់ ដោយរក្សាការកត់ត្រាចំណាយតាមមាតិកានៃចំណាត់ថ្នាក់សេដ្ឋកិច្ចដដែល។ ការបោះផ្សាយអាណត្តិបើកប្រាក់ ត្រូវរៀបចំទៅតាមប្រភេទមុខសញ្ញាចំណាយថវិកា ដោយផ្អែកលើមូលដ្ឋានគណនីតែ១ គឺមិនមែនតាមផ្អែកតាមជំពូក១នោះទេ។ ដូច្នេះ អាណត្តិបើកប្រាក់១ អាចមានអនុគណនីច្រើន ប៉ុន្តែត្រូវស្ថិតក្នុងគណនី១ និងមានគណនីតែ១ប៉ុណ្ណោះ។

១២. <u>ចំនួនទឹកប្រាក់:</u> ជាចំនួនទឹកប្រាក់សរុបទៅតាមមាតិកាថវិកា គិតជាប្រាក់រៀល។

១៣. <u>ឈ្មោះ និងអាស័យដ្ឋានអត្ថគាហក:</u> សូមបំពេញព័ត៌មាននៅក្នុងប្រអប់នេះនូវឈ្មោះអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលផល និងអាស័យដ្ឋានឱ្យបានច្បាស់លាស់។ បើជាក្រុមហ៊ុន ឬសហគ្រាសឯកជន ព័ត៌មានត្រូវផ្អែកលើប៉ាតង់ប្រចាំឆ្នាំនៃអ្នកផ្គត់ផ្គង់ រីឯឈ្មោះអ្នកផ្គត់ផ្គង់ ឬអ្នកទទួលផលត្រូវមានសង្គតិភាពគ្នារវាងប័ណ្ណប៉ាតង់ប្រចាំឆ្នាំនិងឈ្មោះគណនីនៅធនាគារ។

១៤. <u>ឈ្មោះអង្គភាពចំណាយ:</u> បញ្ជាក់ពីឈ្មោះអង្គភាពទទួលបន្ទុកចំណាយផ្ទាល់។

១៥. <u>បែបបទនៃការទូទាត់:</u> ព័ត៌មាននៅក្នុងចំណុចនេះ រតនាគារថ្នាក់កណ្ដាល ឬរតនាគាររាជធានី ខេត្ត ជាអ្នកបំពេញ។

១៦. <u>លេខគណនី:</u> បំពេញនូវលេខគណនីរបស់អត្ថគាហកដែលមានកំណត់នៅក្នុងប្រអប់ ឈ្មោះ និងអាស័យដ្ឋានអត្ថគាហក នៅរតនាគារ ឬធនាគារ។

១៧. <u>អាស័យដ្ឋានរតនាគារ ឬ ធនាគារ:</u> បំពេញនូវឈ្មោះ និងអាស័យដ្ឋានរតនាគារ ឬ ធនាគារដែលអត្ថគាហក បានបើកគណនីរបស់ខ្លួនសម្រាប់ធ្វើការទូទាត់នេះ។

១៨. <u>កម្មវត្ថុចំណាយ:</u> នៅក្នុងខ្លឹមសារនៃកម្មវត្ថុចំណាយ សូមបញ្ជាក់ថាតើចំណាយដែលស្នើសុំទូទាត់ស្ថិតនៅក្នុងកម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព ណាមួយឱ្យបានច្បាស់លាស់។

ចំពោះព័ត៌មានចាំបាច់ដូចបានណែនាំខាងលើ ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបំពេញទៅតាមករណីនៃការអនុវត្តជាក់ស្ដែងរបស់ខ្លួន និងតាមលិខិតគតិយុត្តយោងដែលមានចែងដោយច្បាប់។

## ខ-នីតិវិធីនៃការកត់ត្រាក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ- FMIS

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ជំហានទី១នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាប់ពីឆ្នាំ២០១៦ លើមុខងារចំនួន ០៦ គឺមុខងារវិភាជន៍ថវិកា (BA) មុខងារបញ្ជាទិញ (PO) មុខងារគណនីត្រូវសង (AP) មុខងារគណនីត្រូវទារ (AR) មុខងារសៀវភៅធំ (GL) និង មុខងារគ្រប់គ្រងសាច់ប្រាក់ (CM)។ ក្រោយពីអនុវត្តបានដោយជោគជ័យនូវជំហានទី១ នៅឆ្នាំ២០១៨នេះ FMIS ត្រូវបានពង្រីកវិសាលភាពគ្របដណ្ដប់ដល់ក្រសួងចំនួន១០បន្ថែមទៀត ហើយនឹងបន្តពង្រីកដែនគ្របដណ្ដប់ដល់គ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្តនៅឆ្នាំខាងមុខទៀត។ ក្នុងបរិការណ៍ដែលមានក្រសួង ស្ថាប័ន និងរាជធានី ខេត្តមួយចំនួន ទើបត្រូវបានដាក់ឱ្យអនុវត្តប្រតិបត្តិការចំណាយថវិកាតាមប្រព័ន្ធ FMIS និងមានក្រសួង ស្ថាប័ន និងរាជធានី ខេត្តមួយចំនួននៅមិនទាន់អនុវត្តប្រតិបត្តិការចំណាយតាមប្រព័ន្ធ FMIS ដោយផ្ទាល់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំនូវនីតិវិធីមួយចំនួនដូចខាងក្រោម÷

១-ចំពោះក្រសួង ស្ថាប័នចំនួន១០ ដែលត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ក្នុងឆ្នាំ២០១៨ រាល់ប្រតិបត្តិការចំណាយត្រូវកត់ត្រាចូលក្នុងប្រព័ន្ធ FMIS ដោយក្រសួង ស្ថាប័នសាមីដោយផ្ទាល់។ ក្រសួង ស្ថាប័នទាំងនោះ រួមមាន÷ (១)-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២)-ក្រសួងសុខាភិបាល (៣)-ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (៤)-ក្រសួងអប់រំ យុវជន និងកីឡា (៥)-ក្រសួងកិច្ចការនារី (៦)-ក្រសួងបរិស្ថាន (៧)-ក្រសួងមុខងារសាធារណៈ (៨)-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៩)-ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និង(១០)-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

២-ចំពោះក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនទាន់ត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធFMIS នោះរាល់ប្រតិបត្តិការចំណាយត្រូវកត់ត្រាចូលក្នុងប្រព័ន្ធ FMIS ត្រូវអនុវត្តនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវកត់ត្រានៅរតនាគាររាជធានី ខេត្ត។

គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហ ៥រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ក្រសួង: ១ ..................................

រាជធានី ខេត្ត: ២ ..........................

# អាណត្តិបើកប្រាក់

ការគ្រប់គ្រងឆ្នាំ ២០១៨

លេខកូដប្រព័ន្ធ: ៤ | លេខអាណត្តិ: ៣

| រដ្ឋបាល ៥ | ភូមិសាស្ត្រ ៦ | មុខងារ ៧ | មូលនិធិ ៨ | កម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព ៩ | គម្រោង ១០ |
|---|---|---|---|---|---|
| | | | | | |

| ជំពូក-គណនី-អនុគណនី ១១ | ចំនួនទឹកប្រាក់ ១២ | កម្មវត្ថុចំណាយ-ឈ្មោះសក្ខីប័ត្រ ១៨ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| សរុបរួម: | | ឈ្មោះអង្គភាពចំណាយ: ១៤ |

ឈ្មោះ និងអាសយដ្ឋានអត្ថគាហក: ១៣

របៀបទូទាត់: ☐ បង្វែរ ☐ សាច់ប្រាក់ ១៥

លេខគណនី: ១៦

អាស័យដ្ឋានធនាគារ ឬធនាគារ: ១៧

អាណត្តិនេះកំណត់ត្រឹមទឹកប្រាក់ចំនួន:..........................................................................................................

ហត្ថលេខា និងត្រា របស់អាណាប័ក

កាលបរិច្ឆេទ:

| ទិដ្ឋាការអភិបាលហិរញ្ញវត្ថុ | កន្លែងសម្រាប់គណនេយ្យករ | |
|---|---|---|
| លេខសលាកប័ត្រ:<br>ហត្ថលេខា និងត្រា<br>កាលបរិច្ឆេទ: | ចំនួនទឹកប្រាក់នៃអាណត្តិ: ..........................................<br>ការជំទាស់ និងការដកហូតទុក: ..........................................<br>ចំនួនទឹកប្រាក់ពិតត្រូវបើក: .......................................... | បានឃើញ និងអនុញ្ញាតឱ្យបើកផ្តល់<br>ហត្ថលេខា និងត្រា<br>កាលបរិច្ឆេទ: |

---

ក្រសួង: ..................................

រាជធានី ខេត្ត: ..........................

# អាណត្តិបើកប្រាក់

លេខកូដប្រព័ន្ធ: | លេខអាណត្តិ:

កាលបរិច្ឆេទ:

| រដ្ឋបាល | ភូមិសាស្ត្រ | មុខងារ | មូលនិធិ | កម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព | គម្រោង |
|---|---|---|---|---|---|
| | | | | | |

| ជំពូក-គណនី-អនុគណនី | ចំនួនទឹកប្រាក់ | កម្មវត្ថុចំណាយ-ឈ្មោះសក្ខីប័ត្រ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| សរុបរួម: | | ឈ្មោះអង្គភាពចំណាយ: |

អាណត្តិនេះកំណត់ត្រឹមទឹកប្រាក់ចំនួន:..........................................................................................................

| ឈ្មោះ និងអាសយដ្ឋានអត្ថគាហក: | កន្លែងសម្រាប់គណនេយ្យករ | |
|---|---|---|
| | ចំនួនទឹកប្រាក់នៃអាណត្តិ: ..........................................<br>ការជំទាស់ និងការដកហូតទុក: ..........................................<br>ចំនួនទឹកប្រាក់ពិតត្រូវបើក: .......................................... | របៀបទូទាត់: ☐ បង្វែរ ☐ សាច់ប្រាក់<br>លេខគណនី:<br>អាស័យដ្ឋានធនាគារ ឬធនាគារ: |

| អត្ថគាហក: (ទូទាត់ជាសាច់ប្រាក់) | បានឃើញ និងអនុញ្ញាតឱ្យបើកផ្តល់ |
|---|---|
| ដើម្បីនិមុត្តិ<br>កាលបរិច្ឆេទ: | ហត្ថលេខា និងត្រា<br>កាលបរិច្ឆេទ: |